**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥៧១ ប្រក.កសក

# ប្រកាស

## ស្តីពី

## ការបង្កើតស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ ស្ទឹងត្រែង

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/ រកម/ ០៨០២/ ០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការ អន្តរជាតិ និងមជ្ឈមណ្ឌលពតិមាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានកៅស៊ូត្រសាស្ត្រ និង កែលំអដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និង កែសម្រួលអគ្គនាយកដ្ឋានចំការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីនីតិវិធីការបង្កើត ការចាត់ថ្នាក់ និងការចុះបញ្ជីកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
\ 200 Preah Norodom Blvd , Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone (023) 726 128 ' 726 129, Fax . (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីវិធាននៃការផ្តល់សិទ្ធិប្រើប្រាស់ដីព្រៃរបស់រដ្ឋសម្រាប់ការដាំឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៣៦១ ប្រក.កសក. ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៦០២ ប្រក.កសក.ប ចុះថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពចំណុះនាយកដ្ឋាន វិទ្យាស្ថាន និង ឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំ តាម៉ៅនៃរដ្ឋបាលព្រៃឈើ
- តាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ ។

## សម្រេច

**ប្រការ១** : បង្កើតស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើមួយកន្លែងមានឈ្មោះថា: ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទឹងកែវ មានទីតាំងស្ថិតក្នុងដែនព្រៃបម្រុងទុកអចិន្ត្រៃយ៍ក្នុងឃុំកោះតូច ឃុំបឹងទូក ឃុំម៉ាក់ប្រាង្គ ឃុំស្ទឹងកែវ ឃុំថ្មី និងឃុំព្រៃថ្នង ឃុំត្រពាំងប្លាំង ស្រុកកំពត និងឃុំអណ្តូងខ្មែរ ស្រុកកំពង់បាយ ខេត្តកំពត ។

**ប្រការ២** : ប្រកាសនេះមានគោលបំណង:

- ស្តារព្រៃឈើឡើងវិញ តាមរយៈការដាំឈើសម្រាប់អភិវឌ្ឍប្រកបដោយនិរន្តរភាពនូវ សេដ្ឋកិច្ច សង្គម និង បរិស្ថាន
- អភិវឌ្ឍចំណេះដឹងបច្ចេកទេសដាំឈើ បំផុសការចូលរួមដាំឈើ និង ផ្តល់ការងារធ្វើដល់សហគមន៍មូលដ្ឋាន ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាជនក្នុងតំបន់
- ទប់ស្កាត់បង្ក្រាប និង លុបបំបាត់ការកាប់រាន ការដុត ការឈូសឆាយ និង ការហ៊ុមព័ទ្ធកាន់កាប់ដីព្រៃឈើ ដើម្បីធ្វើជាកម្មសិទ្ធិ
- ទប់ស្កាត់ការហូរច្រោះដីជាតិដី និង កែលំអដីតាមរយៈដំណុះព្រៃដាំ និងអភិវឌ្ឍជីវចម្រុះ
- កាត់បន្ថយការប្រើប្រាស់ព្រៃឈើធម្មជាតិ តាមរយៈបង្កើនផលិតផលឈើពីព្រៃដាំ
- ចូលរួមចំណែកក្នុងយន្តការអភិវឌ្ឍស្អាត ឬ យន្តការផ្សេងៗទៀត ដើម្បីកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់លើភពផែនដី និង ទប់ស្កាត់ការប្រែប្រួលអាកាសធាតុ
- ទ្រទ្រង់សកម្មភាពផ្សេងៗ រួមមាន ការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ បច្ចេកទេស ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល និង អភិវឌ្ឍសហគមន៍មូលដ្ឋាន ។

**ប្រការ៣** : ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទឹងកែវ មានផ្ទៃក្រឡាសរុប ៩.៧៤៣ (ប្រាំបួនពាន់ប្រាំពីររយសែសិបបី) ហិកតា ដូចមាន ផែនទីមាត្រដ្ឋាន ១ : ១៤០.០០០ ភ្ជាប់មកជាឧបសម្ព័ន្ធ ៖

<u>តំបន់ទី១ :</u> ផ្ទៃដីទំហំ ២.៣៥៦ ហិកតា មានប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចនិយាមកាដូចខាងក្រោមនេះ ៖

1 (392057 ,1169525) 2 (393742 ,1169602) 3 (395331 , 1168824) 4 (395658 ,1168864) 5 (396884 , 1169458) 6 (398288 , 1168870) 7 (400086,1169997) 8 (402830,1169998) 9 (404122,1170032) 10 (405615, 1171918) 11 (407037, 1176699) 12 (407841, 1175970) 13 (407045, 1175152) 14 (407947, 1172108) 15 (404268 , 1169165) 16 (402910,1168882) 17 (401325,1167656) 18 (398609,1167750) 19 (396951 ,1168390) 20 (396505 , 1168376) 21(395804,1168244) 22(395448,1168370) 23(395065,1168400) 24 (394054, 1168902) 25(393525, 1168958) 26(392587,1168665) 27(391709,1169119) ,

**តំបន់ទី២ :** ផ្ទៃដីទំហំ ៧.៣៨៧ ហិកតា មានប្រព័ន្ធខ្សែព្រំបិទ កំណត់ដោយបណ្តាចំណុចនិយាមកាដូចខាងក្រោមនេះ ៖
1 ( 421185,1183366) 2 (420376 ,1183679) 3 (420745, 1185999) 4 (417013 ,1185972) 5 (417006 , 1186998) 6 (408275 , 1187046) 7 (408556,1188031) 8 (407264,1191841) 9 (407403,1193043) 10 (407045, 1194790) 11 (406771,1197431) 12 (406510,1197952) 13 (406434,1199635) 14 (409843,1198727) 15 (410101, 1197793) 16 (410029, 1194505) 17 (410640, 1193928) 18 (410631, 1191164) 19 (412921, 1191162) 20 (416045, 1190696) 21(416538, 1189228) 22(417386, 1188167) 23 (422377, 1187476) 24 (422077, 1184988) 25 (422455,1184167) ។

**ប្រការ៤** : ស្ថានីយផ្សព្វផ្សាយ និង ស្តារព្រៃឈើស្ទឹងកែវ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ មានភារកិច្ចដូចតទៅ ៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេស វិទ្យាសាស្ត្រ និងធ្វើការបណ្តុះកូនឈើ ដាំឈើ ថែរក្សាការពារ និងប្រមូលផល អនុផល ចម្ការព្រៃដាំ
- សហការជាមួយដៃគូអភិវឌ្ឍ ដៃគូវិនិយោគក្នុងប្រទេស ឬ ក្រៅប្រទេសក្នុងការដាំដុះ ផលិត កែច្នៃ និងប្រមូលផល អនុផល ចម្ការព្រៃដាំ
- ជួយបណ្តុះបណ្តាល និង ផ្សព្វផ្សាយបច្ចេកទេសដាំដុះ ផលិត កែច្នៃ និង ផ្តល់មុខរបរដល់សហគមន៍មូលដ្ឋាន
- កៀរគរ ទាក់ទាញ ការចូលរួមគាំទ្រ និង ទទួលជំនួយឧបត្ថម្ភពីគ្រប់មជ្ឈដ្ឋានជាតិ និង អន្តរជាតិ ។

**ប្រការ៥** : ដំណើរការ និងការគ្រប់គ្រងស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ៦** : ទំហំផ្ទៃដីនៃស្ថានីយនេះ អាចនឹងមានការប្រែប្រួលគឺអាស្រ័យទៅនឹងស្ថានភាពជាក់ស្តែង ហើយត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៧** : ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៨**: អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្មខេត្តកំពតត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

ជ័ន្ទ សារុន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងបរិស្ថាន
- សាលាខេត្តកំពត
- ដូចប្រការ៨
- ឯកសារ-កាលប្បវត្តិ